អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គភាពជនរងគ្រោះ**

**សារគន្លឹះសម្រាប់អ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២**

1. នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩, គណៈកម្មាធិការកិច្ចប្រជុំពេញអង្គនៃអ.វ.ត.កបានសម្រេចផ្លាស់ប្តូរ ពេលផុតកំណត់សម្រាប់ការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿង បច្ចុប្បន្ន ដែលកំពុងស្ថិតក្នុងការស៊ើបអង្កេតដោយអវតក (សំណុំរឿង០០២)។ ពេលផុតកំណត់ថ្មីនេះនឹង មានរយៈពេល១៥ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីការបញ្ចប់ដំណើរការស៊ើបអង្កេត។ **បច្ចុប្បន្ននេះ គណៈកម្មាធិការកិច្ចប្រជុំពេញអង្គរំពឹងថា ដំណើរការស៊ើបអង្កេតនឹងបញ្ចប់នៅចុងឆ្នាំ២០០៩។**

2. ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណា ដែលបានដាក់បន្ទាប់ពីពេលផុតកំណត់នេះនឹងមិនត្រូវបានពិចារណាដោយចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងឡើយ។

3. នេះមានន័យថា បុគ្គលណាដែលចង់ក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ គួរដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួននៅអង្គភាពជនរងគ្រោះ **ឲ្យបានលឿនបំផុតតាម ដែលអាចធ្វើទៅបាន** ធ្វើម៉េចឲ្យបានមុនពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០០៩។ ធ្វើបែបនេះគឺដើម្បីទទួលបានទូវ ចំណាប់អារម្មណ៍កាន់តែច្រើន និងផលប្រយោជន៍ផ្សេងៗទៀតពីការដាក់ឯកសាររបស់អង្គភាពជនរងគ្រោះ និងការិយាល័យសហចៅក្រមស៊ើបអង្កេត។ វាក៏ជួយផ្តល់ពេលវេលាបន្ថែមទៀតសម្រាប់ការរុករកព័ត៌មាន ពិស្តារបន្ថែម ដែលបានផ្តល់ដោយអ្នកដាក់ពាក្យ ប្រសិនបើមានករណីនេះកើតឡើង។

4. សំណុំរឿងដែលដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនេះ (សំណុំរឿង០០២) ពាក់ព័ន្ធនឹងការចោទប្រកាន់ទៅ លើ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន។ បុគ្គលទាំងនេះគឺជាអតីតមេដឹកនាំជាន់ខ្ពស់នៃរបប ខ្មែរក្រហម។ បុគ្គលទាំងនេះត្រូវបានចោទអំពីឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិធ្ងន់ធ្ងរ ជាលទ្ធផលនៃការទទួល ខុសត្រូវរបស់ពួកគេចំពោះការបង្កើតគោលនយោបាយ និងសកម្មភាពផ្សេងៗក្នុងរបបខ្មែរក្រហម។

5. មានតែពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានលក្ខណៈពេញលេញ និងពាក់ព័ន្ធនឹង ការស៊ើបអង្កេតបច្ចុប្បន្នប៉ុណ្ណោះនឹងត្រូវទទួលយកដោយសហចៅក្រមស៊ើបអង្កេត។ ព័ត៌មានចាំបាច់ ដែលត្រូវបំពេញរួមមានៈ
    - ឈ្មោះជនរងគ្រោះម្នាក់ ឬច្រើននាក់ និងឈ្មោះអ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី។
    - អាសយដ្ឋាននៅកម្ពុជារបស់អ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។
    - ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។
    - រាល់ព័ត៌មាន ដែលអាចរកបាន ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមួយ ឬច្រើន ដូចដែលបានចោទដោយ អ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (តុលាការចាំបាច់ត្រូវកំណត់ថា អ្វី ដែលបានកើតឡើងចំពោះអ្នកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនានា ដែលកំពុងត្រូវបានស៊ើបអង្កេតដោយតុលាការ)។ ការពណ៌នា

អំពីឧក្រិដ្ឋកម្មគួរត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់ និងមានលក្ខណៈសមស្របពាក់ព័ន្ធនឹង ទីតាំង (រួមមានឈ្មោះទីកន្លែង ដែលឧក្រិដ្ឋកម្មបានកើតឡើង និងយ៉ាងហោចណាស់ ឈ្មោះស្រុក និងខេត្តនៃទីកន្លែងនោះ) និងឆ្នាំ ដែលឧក្រិដ្ឋកម្មនោះបានកើតឡើង។

- **ភស្តុតាងអត្តសញ្ញាណ**នៃបុគ្គល ដែលដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នេះអាចជាសំណៅថតចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬលិខិតចេញដោយ អាជ្ញាធរសង្កាត់/ឃុំ ឬអាជ្ញាធរខ្ពស់ជាងហ្នឹង។ បើអាចធ្វើបាន លិខិតនោះគួរត្រូវបាន បោះត្រាត្រឹមត្រូវ។
- ប្រសិនបើអាចរកបាន រាល់ឯកសារ ដែលគាំទ្រដល់ព័ត៌មានផ្តល់ដោយអ្នកដាក់ពាក្យបណ្តឹង សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ឧទាហរណ៍ រូបថតនៃជនរងគ្រោះ។
- សម្រាប់គោលការណ៍ណែនាំពិស្តារស្តីអំពីរបៀបបំពេញទំរង់បែបបទព័ត៌មានជនរងគ្រោះ សូមទំនាក់ទំនងជាមួយអង្គភាពជនរងគ្រោះ (តាមព័ត៌មានខាងក្រោម)។

6. ចំពោះបុគ្គល ដែលមិនប្រាថ្នាចង់ចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីទេនោះក៏នៅតែអាចដាក់ពាក្យ បណ្តឹងភ្ជាប់មកនូវព័ត៌មាន និង/ឬភស្តុតាងដែលមានប្រយោជន៍ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្ត ដោយខ្មែរក្រហម។ ភស្តុតាងទាំងនេះនឹងត្រូវបានពិចារណាដោយសហព្រះរាជអាជ្ញា ហើយ បើសមស្រប ពួកគេនឹងសម្រេចដោយប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ថាតើត្រូវច្រានចោលពាក្យបណ្តឹងនោះ, បញ្ចូល ពាក្យបណ្តឹងនោះទៅក្នុងការស៊ើបអង្កេត ដែលកំពុងតែដំណើរការ, រៀបចំការស៊ើបអង្កេតថ្មីមួយទៀត ឬ បញ្ជូនពាក្យបណ្តឹងនោះផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីប្រើប្រាស់ក្នុងការស៊ើបអង្កេត ដែលកំពុង ដំណើរការនោះ។ អ្នកដាក់ពាក្យបណ្តឹងអាចត្រូវបានកោះអញ្ជើញមកធ្វើជាសាក្សីដោយសហព្រះរាជអាជ្ញា។ គ្មានពេលវេលាកំណត់ទេក្នុងការដាក់ពាក្យបណ្តឹង។ ទោះជាយ៉ាងនេះក្តី ព័ត៌មាននេះគួរត្រូវបានផ្តល់ឲ្យ ឆាប់បំផុតតាមអាចធ្វើទៅបាន ជាប្រយោជន៍ដើម្បីបង្កើនលទ្ធភាពដែលថា ការិយាល័យសហព្រះរាជអាជ្ញា អាចពិចារណាលើព័ត៌មានហ្នឹង។

7. ចំពោះអ្នកដែលចាប់អារម្មណ៍ក្លាយខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬដាក់ពាក្យបណ្តឹងគួរបំពេញទំរង់បែបបទព័ត៌មានជនរងគ្រោះ។ ទំរង់បែបបទនេះមាននៅអង្គភាពជនរងគ្រោះ និងនៅលើគេហទំព័ររបស់អ.វ.ត.ក ដែលមានជាភាសាខ្មែរ, អង់គ្លេស និងបារាំង។ ក្នុងនោះក៏មានគោលការណ៍ណែនាំ ដើម្បីពន្យល់អំពីខ្លឹមសារ ទំរង់បែបបទនេះដោយពិស្តារដែរ។ ទំរង់បែបបទ និងគោលការណ៍ណែនាំនេះគឺអាចរកបានដោយឥតគិតថ្លៃ ហើយ គ្មានការចំណាយអ្វីទាំងអស់ក្នុងដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង/ឬ ដើម្បីក្លាយខ្លួនជាអ្នកដាក់ពាក្យបណ្តឹង។

8. នៅពេលដែលបំពេញរួច ទំរង់បែបបទគួរយកទៅដាក់នៅអង្គភាពជនរងគ្រោះ។ ដើម្បីទទួលបាននូវទំរង់ បែបបទ និងគោលការណ៍ណែនាំ និងមតិយោបល់បន្ថែម សូមទាក់ទងអង្គភាពជនរងគ្រោះតាមរយៈ៖

- ទូរស័ព្ទលេខ៖ 012 842 861 ឬ 097 742 4218
- ឬអញ្ជើញមកមជ្ឈមណ្ឌលព័ត៌មានដូចមានអាសយដ្ឋានខាងក្រោម៖

**អង្គភាពជនរងគ្រោះ**

ផ្ទះលេខ៦A ផ្លូវ២១ សង្កាត់ទន្លេបាសាក់ I

ខណ្ឌចំការមន ភ្នំពេញ កម្ពុជា

អង្គភាពជនរងគ្រោះត្រៀមខ្លួនចាំជួយលោក-អ្នក ដែលចង់បំពេញទំរង់បែបបទព័ត៌មានជនរងគ្រោះ។ ការិយាល័យយើងខ្ញុំចាប់បើកពីម៉ោង០៨:០០ព្រឹក រហូតដល់ម៉ោង ០៥:០០ ល្ងាច ពីថ្ងៃច័ន្ទ រហូតដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាក។

*គ្មានការចំណាយអ្វីទាំងអស់ក្នុងការដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឬក្លាយខ្លួនជាអ្នកដាក់ពាក្យបណ្ដឹង។*